ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៨៨៥...សហវ.ប្រក

# ប្រកាស

## ស្តីពី

## ក្រមសីលធម៌លទ្ធកម្ម

### ទេសរដ្ឋមន្ត្រី

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664    Fax : 855-23-427 798

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងរួមចំណែកធានាឱ្យការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ប្រព្រឹត្តទៅប្រកបដោយសុច្ចរិតភាព តម្លាភាព គណនេយ្យភាព ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីគោលការណ៍នៃក្រមសីលធមិលទ្ធកម្មសម្រាប់ដាក់ឱ្យអនុវត្តក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះ គណៈកម្មាធិការលទ្ធកម្ម ក្រុមលទ្ធកម្ម មន្ត្រីលទ្ធកម្ម និងអ្នកដេញថ្លៃ ព្រមទាំងបុគ្គលដទៃទៀតដែលមានការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ។

**ប្រការ ៤.-**

វាក្យស័ព្ទបច្ចេកទេសក្នុងប្រកាសនេះត្រូវបានកំណត់ន័យដូចតទៅ:

- **ក្រមសីលធមិលទ្ធកម្ម :** សំដៅដល់ក្រមដែលអ្នកចូលរួមពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈត្រូវយល់ដឹង និងអនុវត្តដោយស្មោះត្រង់តាមបទប្បញ្ញត្តិគតិយុត្តជាធរមាន និងអនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទី និងមុខងាររបស់ខ្លួន។
- **គណៈកម្មាធិការលទ្ធកម្ម:** សំដៅដល់ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការលទ្ធកម្ម។
- **ក្រុមលទ្ធកម្ម:** សំដៅដល់ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមលទ្ធកម្មរបស់អង្គភាពថវិកា។
- **មន្ត្រីលទ្ធកម្ម :** សំដៅដល់ប្រធាន អនុប្រធាន និងមន្ត្រីទាំងអស់របស់អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម។
- **ទំនាស់ផលប្រយោជន៍ :** សំដៅដល់ផលប្រយោជន៍ផ្ទាល់ខ្លួនដែលខ្លួនឯង ឬអ្នកដទៃយល់ថាប៉ះពាល់ដល់អព្យាក្រឹត្យភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួន។
- **អំពើពុករលួយ :** សំដៅដល់ការស្នើក ឬការទទួលវត្ថុមានតម្លៃ ដើម្បីធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពមន្ត្រីសាធារណៈនៅក្នុងដំណើរការដេញថ្លៃ ប្រគល់កិច្ចសន្យា ឬអនុវត្តកិច្ចសន្យា។
- **អំពើឃុបឃិត:** សំដៅដល់ផែនការ ឬជាការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរ ឬច្រើន ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិត ឬតម្លៃគ្មានលក្ខណៈប្រកួតប្រជែងពិតប្រាកដ ឬធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។
- **អំពើបន្លំ:** សំដៅដល់ការបកស្រាយបំភ្លៃហេតុការណ៍ ដើម្បីធ្វើឱ្យមានឥទ្ធិពលលើដំណើរការវាយតម្លៃ ប្រគល់កិច្ចសន្យា ឬដំណើរការអនុវត្តកិច្ចសន្យា និងការចូលរួមចំណែកក្នុងអំពើឃុបឃិតជាមួយ អ្នកដេញថ្លៃ ឬទីប្រឹក្សា (មុន ឬ ក្រោយពេលដាក់សំណើសុំដេញថ្លៃ) ធ្វើឱ្យខូចប្រយោជន៍របស់ជាតិ។



ԽՂ

- **អំពើបង្ខិតបង្ខំ**៖ សំដៅដល់ការហាមឃាត់ ឬការគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោល ធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គល ឬខូចខាតទ្រព្យសម្បត្តិរបស់បុគ្គល ដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈរបស់បុគ្គលនោះ ឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

## ជំពូកទី ២
## គោលការណ៍នៃក្រមសីលធម៌លទ្ធកម្ម

**ប្រការ ៥.-**

គណៈកម្មាធិការលទ្ធកម្ម ក្រុមលទ្ធកម្ម មន្ត្រីលទ្ធកម្ម និងអ្នកដេញថ្លៃ ព្រមទាំងបុគ្គលដទៃទៀតដែលមានការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍នៃក្រមសីលធម៌លទ្ធកម្មដូចខាងក្រោម៖

- មិនមានទំនាក់ទំនងណាមួយដែលអាចចាត់ទុកថាជាទំនាស់ផលប្រយោជន៍នៅពេលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- មិនត្រូវប្រព្រឹត្តអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំពាក់ព័ន្ធនឹងដំណើរការកិច្ចលទ្ធកម្មសាធារណៈ
- មិនមានការផ្តល់លាភការណាមួយពាក់ព័ន្ធនឹងដំណើរការលទ្ធកម្មសាធារណៈឱ្យទៅភ្នាក់ងារទីប្រឹក្សា និយោជិត ឬញាតិសន្តាន ឬមន្ត្រីពាក់ព័ន្ធដែលបានចូលរួមក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈ
- ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគំរូស្តង់ដារឯកសារដេញថ្លៃដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រូវផ្តល់ឱកាសនិងសិទ្ធិស្មើភាពគ្នាដល់អ្នកចូលរួមដេញថ្លៃក្នុងកិច្ចលទ្ធកម្មសាធារណៈ
- ត្រូវជៀសវាងដាច់ខាតនូវការចែងពីលក្ខខណ្ឌមិនស្មើភាពគ្នាក្នុងការប្រកួតប្រជែង ឬមានការរើសអើងចំពោះអ្នកចូលរួមដេញថ្លៃ នៅពេលរៀបចំឯកសារដេញថ្លៃ ឬសំណើចំណាប់អារម្មណ៍
- ត្រូវធានាឱ្យបាននូវតម្លៃសាច់ប្រាក់ក្នុងលក្ខខណ្ឌនៃការចំណាយ គុណភាព និងពេលវេលា
- ត្រូវផ្តល់ជូនដល់អ្នកចូលរួមដេញថ្លៃនូវព័ត៌មានពិត មិនលំអៀង និងយុត្តិធម៌ ដើម្បីជៀសវាងនូវការយល់ច្រឡំ ឬការបកស្រាយខុស
- ត្រូវវាងការធ្វើអធិការកិច្ច ឬការធ្វើសវនកម្មពីស្ថាប័នមានសមត្ថកិច្ចលើរាល់លិខិតស្នាមដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- ត្រូវធានាថាគ្រប់អ្នកដេញថ្លៃ ត្រូវទទួលបាននូវយុត្តិធម៌និងអព្យាក្រឹតភាព ហើយត្រូវជៀសវាងចំណាត់ការណាមួយដែលទប់ស្កាត់មិនឱ្យដំណើរការនៃការប្រកួតប្រជែងប្រព្រឹត្តទៅប្រកបដោយមានប្រសិទ្ធភាព។

**ប្រការ ៦.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈត្រូវទទួលខុសត្រូវ ដូចខាងក្រោម៖

- ជំរុញឱ្យគ្រប់ស្ថាប័នអនុវត្តលទ្ធកម្មនិងអ្នកដេញថ្លៃត្រូវអនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវដោយអនុលោមតាមច្បាប់ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- បណ្តុះបណ្តាលមន្ត្រីរបស់ស្ថាប័នអនុវត្តលទ្ធកម្មនិងក្រុមលទ្ធកម្មនៃអង្គភាពថវិកាឱ្យមានចំណេះដឹងពីជំនាញលទ្ធកម្ម

- អង្កេត ត្រួតពិនិត្យ និងតាមដានលើការគោរពអនុវត្តក្រមសីលធម៌វិជ្ជាជីវៈលទ្ធកម្មចំពោះមន្ត្រីរបស់ស្ថាប័នអនុវត្តលទ្ធកម្មនិងក្រុមលទ្ធកម្មនៃអង្គភាពថវិកាដែលមានការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មព្រមទាំងមានវិធានការដោះស្រាយចំពោះអ្នកប្រព្រឹត្តខុសក្រមសីលធម៌វិជ្ជាជីវៈលទ្ធកម្ម។

**ប្រការ ៧.-**

ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ដែលជាប្រតិបត្តិករអនុវត្តផ្ទាល់លើដំណើរការកិច្ចលទ្ធកម្មសាធារណៈត្រូវទទួលខុសត្រូវជាសារវ័ន្ត ដូចខាងក្រោម៖

- អនុវត្តឱ្យបានត្រឹមត្រូវតាមគំរូឯកសារដេញថ្លៃដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវធានាឱ្យបាននូវការគោរពក្រមសីលធម៌វិជ្ជាជីវៈលទ្ធកម្ម
- ធានាថាគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្មត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយឯករាជ្យ និងមិនមានរងនូវឥទ្ធិពល ឬការជ្រៀតជ្រែកណាមួយឡើយ
- មិនត្រូវប្រើសិទ្ធិអំណាច ឬមុខតំណែងរបស់ខ្លួនដើម្បីផលប្រយោជន៍ណាមួយឡើយ
- ធានាថារាល់ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវផ្អែកលើការមានផែនការលទ្ធកម្មជាមុន
- ធានាថារាល់ការវាយតម្លៃលើសំណើដេញថ្លៃត្រូវបានធ្វើឡើងដោយភាពម៉ត់ចត់ត្រឹមត្រូវ យុត្តិធម៌ និងមិនមានការជ្រៀតជ្រែកពីបុគ្គលមានឥទ្ធិពលណាមួយឡើយ។

**ប្រការ ៨.-**

គណៈកម្មាធិការលទ្ធកម្មត្រូវ៖

- ចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈលទ្ធកម្មនៅគ្រប់ពេលចូលរួមក្នុងការវាយតម្លៃសំណើដេញថ្លៃ
- ប្រកាន់ភ្ជាប់នូវគោលការណ៍នៃក្រមសីលធម៌វិជ្ជាជីវៈលទ្ធកម្មជាធរមាន
- មិនពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំពាក់ព័ន្ធនឹងដំណើរការកិច្ចលទ្ធកម្មសាធារណៈ
- មិនត្រូវជ្រៀតជ្រែក ឬអន្តរាគមន៍ណាមួយដែលធ្វើឱ្យជះឥទ្ធិពលដល់ដំណើរការលទ្ធកម្មសាធារណៈ
- ធានាលើការវាយតម្លៃសំណើដេញថ្លៃធ្វើឡើងត្រឹមត្រូវទៅតាមលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងឯកសារដេញថ្លៃ
- ជៀសវាងដាច់ខាតនូវទំនាស់ផលប្រយោជន៍
- មិនត្រូវទម្លាយការសម្ងាត់ ឬព័ត៌មានផ្ទៃក្នុងដោយផ្ទាល់ ឬដោយប្រយោលដល់អ្នកដេញថ្លៃ ឬអ្នកដែលមានបំណងចូលរួមដេញថ្លៃណាមួយឡើយ។

**ប្រការ ៩.-**

មន្ត្រីអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មត្រូវ៖

- ប្រកាសថាខ្លួនមិនមានទំនាក់ទំនង ឬឃុបឃិតជាមួយអ្នកដេញថ្លៃណាមួយឡើយ
- ធានាឱ្យបាននូវសុច្ចរិតភាពដល់អ្នកដេញថ្លៃប្រកបដោយភាពយុត្តិធម៌ គ្មានការរើសអើង និងត្រូវផ្តល់ឱកាសស្មើគ្នាដល់អ្នកដេញថ្លៃដែលចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ
- មិនត្រូវស្ថិតក្រោមឥទ្ធិពល ឬការជ្រៀតជ្រែកលើសកម្មភាពណាមួយដែលនាំឱ្យជះឥទ្ធិពលដល់ដំណើរការ

កិច្ចលទ្ធកម្មសាធារណៈពីបុគ្គលណាមួយឡើយ

- មិនត្រូវទម្លាយការសម្ងាត់ ឬពត៌មានផ្ទៃក្នុងដោយផ្ទាល់ ឬដោយប្រយោលដល់អ្នកដេញថ្លៃ ឬអ្នកដែលមានបំណងចូលរួមដេញថ្លៃ
- មិនត្រូវពិភាក្សាការងារលទ្ធកម្មជាមួយអ្នកដេញថ្លៃ ឬអ្នកដែលមានបំណងចូលរួមដេញថ្លៃលើកលែងតែមានលិខិតច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីលទ្ធកម្ម
- មិនត្រូវបំផ្លាញ ធ្វើឲ្យខូចខាត លាក់ទុក លុបចោល ឬកែប្រែមិនសមស្របនូវឯកសារលទ្ធកម្មផ្លូវការណាមួយឡើយ
- មិនត្រូវទារឬទទួលប្រាក់ ឬស្នើសុំប្រាក់ថ្លៃធ្វើដំណើរ ថ្លៃអាហារ ការកំសាន្ត អំណោយ ការយកចិត្តទុកដាក់ ឬវត្ថុមានតម្លៃពីអ្នកដេញថ្លៃ ឬអ្នកដែលមានបំណងចូលរួមដេញថ្លៃ ឬអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ
- មិនត្រូវសន្យាទទួលធ្វើការងារជូនអ្នកដេញថ្លៃ អ្នកដែលមានបំណងចូលរួមដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ
- មិនត្រូវណែនាំបុគ្គលណាម្នាក់ឲ្យរំលោភច្បាប់និងនីតិវិធីលទ្ធកម្មសាធារណៈជាធរមានឡើយ
- មិនត្រូវប្រាស្រ័យទាក់ទងការងារណាមួយដែលអាចធ្វើឲ្យមានឥទ្ធិពលចំពោះការធ្វើសេចក្តីសម្រេចលើដំណើរការកិច្ចលទ្ធកម្ម។

**ប្រការ ១០.-**

ក្រុមលទ្ធកម្មត្រូវៈ

- ចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មនៅគ្រប់ពេលចូលរួមក្នុងការវាយតម្លៃ សំណើដេញថ្លៃ
- ប្រកាន់ភ្ជាប់នូវគោលការណ៍នៃក្រមសីលធម៌លទ្ធកម្មជាធរមាន
- មិនពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំពាក់ព័ន្ធនឹងដំណើរការកិច្ចលទ្ធកម្មសាធារណៈ
- មិនត្រូវជ្រៀតជ្រែក ឬអន្តរាគមន៍ណាមួយដែលធ្វើឲ្យជះឥទ្ធិពលដល់ដំណើរការលទ្ធកម្មសាធារណៈ
- ធានាលើការវាយតម្លៃសំណើដេញថ្លៃធ្វើឡើងត្រឹមត្រូវទៅតាមលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងឯកសារដេញថ្លៃ
- ជៀសវាងដាច់ខាតនូវទំនាស់ផលប្រយោជន៍
- រក្សាការសម្ងាត់លើដំណើរការវាយតម្លៃសំណើដេញថ្លៃ រហូតដល់ការប្រកាសលទ្ធផលអ្នកដេញថ្លៃឈ្នះជាផ្លូវការ
- ធានាឲ្យបាននូវសុច្ចរិតភាពដល់អ្នកដេញថ្លៃប្រកបដោយភាពយុត្តិធម៌ គ្មានការរើសអើង និងត្រូវផ្តល់ឱកាសស្មើគ្នាដល់អ្នកដេញថ្លៃដើម្បីចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ
- មិនត្រូវស្ថិតក្រោមឥទ្ធិពល ឬការជ្រៀតជ្រែកលើសកម្មភាពណាមួយដែលនាំឲ្យជះឥទ្ធិពលដល់ដំណើរការកិច្ចលទ្ធកម្មសាធារណៈពីបុគ្គលណាមួយឡើយ។



hn

**ប្រការ ១១.-**

អ្នកដេញថ្លៃដែលចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ ត្រូវៈ

- ចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្ម ហើយត្រូវភ្ជាប់មកជាមួយសំណុំឯកសារនៃសំណើដេញថ្លៃ
- ស្វែងយល់និងគោរពតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈនិងកាតព្វកិច្ចដែលបានកំណត់ក្នុងឯកសារដេញថ្លៃនិងឯកសារកិច្ចសន្យា
- មិនត្រូវផ្តល់សំណូក ឬឃុបឃិតជាមួយអ្នករាជការសាធារណៈ ឬជាមួយអ្នកដេញថ្លៃដទៃទៀត។

**ប្រការ ១២.-**

គំរូសេចក្តីប្រកាសក្រមសីលធម៌លទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម ក្រុមលទ្ធកម្ម មន្ត្រីលទ្ធកម្ម និងអ្នកដេញថ្លៃ មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**ប្រការ ១៣.-**

គណៈកម្មាធិការលទ្ធកម្ម ក្រុមលទ្ធកម្ម មន្ត្រីលទ្ធកម្ម និងអ្នកដេញថ្លៃ ព្រមទាំងបុគ្គលដទៃទៀតដែលមានការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈដែលមិនគោរពក្រមសីលធម៌លទ្ធកម្ម ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាលនិងទោសទណ្ឌផ្សេងទៀតស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
-ដូចក្នុងប្រការ១៣ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្ត



៦២

*ឧបសម្ព័ន្ធ ១*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*គំរូសេចក្តីប្រកាសក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ*

**សេចក្តីប្រកាសក្រមសីលធម៌លទ្ធកម្ម**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ................................ មុខងារជា ..................................................

សូមធ្វើការអះអាង នៅក្នុងការចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈថា :

១- ខ្ញុំបាទ/ នាងខ្ញុំមិនមានទំនាក់ទំនងណាមួយដែលអាចចាត់ទុកថាជាទំនាស់ផលប្រយោជន៍ ដូចមានចែងក្នុងឯកសារដេញថ្លៃ។

២- ប្រសិនបើខ្ញុំបាទ/ នាងខ្ញុំដឹងអំពីលទ្ធភាពដែលអាចកើតមាននូវទំនាស់ផលប្រយោជន៍នេះ ខ្ញុំបាទ/ នាងខ្ញុំត្រូវរាយការណ៍ជាបន្ទាន់ទៅស្ថាប័នអនុវត្តលទ្ធកម្មសាមី។

៣- ខ្ញុំបាទ/ នាងខ្ញុំ មិនប្រព្រឹត្តអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬ អំពើបង្ខិតបង្ខំពាក់ព័ន្ធនឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/ សហគ្រាសរបស់ខ្ញុំបាទ/ នាងខ្ញុំឡើយ។

៤- ខ្ញុំបាទ/ នាងខ្ញុំយល់ច្បាស់អំពីកាតព្វកិច្ចក្នុងការអនុញ្ញាតឱ្យស្ថាប័នមានសមត្ថកិច្ច ធ្វើអធិការកិច្ចលើរាល់លិខិតស្នាមដែលពាក់ព័ន្ធនឹងការរៀបចំដាក់សំណើដេញថ្លៃ និងកិច្ចសន្យាណាមួយជាលទ្ធផលនៃការដាក់សំណើដេញថ្លៃនេះ ដោយមិនគិតថា ខ្ញុំបាទ/ នាងខ្ញុំទទួលបាន ឬមិនទទួលបានការសម្រេចប្រគល់កិច្ចសន្យា។

៥- ខ្ញុំបាទ/ នាងខ្ញុំ សហការី ភ្នាក់ងារម្ចាស់ភាគហ៊ុន ដៃគូរ ឬញាតិសន្តានរបស់ខ្ញុំបាទ/ នាងខ្ញុំ មិនមានការផ្តល់លាភការណាមួយពាក់ព័ន្ធនឹងដំណើរការដេញថ្លៃនេះឱ្យភ្នាក់ងារ ទីប្រឹក្សា និយោជិត ឬញាតិសន្តានគាត់ ឬ/និងមន្ត្រីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចដំណើរការនៃការដេញថ្លៃនេះ។

ធ្វើនៅ.................ថ្ងៃទី..........ខែ...........ឆ្នាំ ២០..........

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**



*ឧបសម្ព័ន្ធ ២*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*គំរូសេចក្តីប្រកាសក្រមសីលធម៌លទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម/មន្ត្រីលទ្ធកម្ម*

**សេចក្តីប្រកាសក្រមសីលធម៌លទ្ធកម្ម**

យើងខ្ញុំសូមធ្វើការអះអាងថា៖

១.ក្នុងអំឡុងពេលដំណើរការលទ្ធកម្ម និងការវាយតម្លៃសំណើដេញថ្លៃសម្រាប់ទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា យើងខ្ញុំត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌លទ្ធកម្ម។

២.នៅក្នុងការអនុវត្តតួនាទីរបស់យើងខ្ញុំ យើងខ្ញុំមិនទទួលនូវផលប្រយោជន៍ទោះជារូបិយវត្ថុ ឬជាសម្ភារៈពីសំណាក់ស្ថាប័ន អ្នកដេញថ្លៃ ឬទីប្រឹក្សាណាមួយនោះទេ ក្រៅពីប្រាក់បៀវត្សផ្លូវការដែលយើងខ្ញុំបានទទួលក្នុងឋានៈជាអ្នករាជការសាធារណៈ។

៣.សហសេវិក សហការី ឬញាតិសន្តានរបស់យើងខ្ញុំ មិនបានទទួលនូវផលប្រយោជន៍ទោះជារូបិយវត្ថុ ឬជាសម្ភារពីសំណាក់ស្ថាប័នខាងក្រៅ អ្នកដេញថ្លៃ ឬទីប្រឹក្សាណាមួយនោះទេ ក្រៅពីប្រាក់បៀវត្សផ្លូវការរបស់ពួកគេឡើយ។

៤.យើងខ្ញុំមិនប្រព្រឹត្តនូវអំពើដែលនាំឱ្យមានអំពើបន្លំ ពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំនានា នៅក្នុងដំណើរការ កិច្ចលទ្ធកម្មនោះទេ ហើយយើងខ្ញុំមានកាតព្វកិច្ចរាយការណ៍ពីការប្រព្រឹត្តនេះ ប្រសិនបើយើងខ្ញុំបានដឹង។

៥.មិនមានទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ទោះជាចំពោះយើងខ្ញុំ អ្នកដេញថ្លៃ ឬទីប្រឹក្សាដែលត្រូវបានសម្រេចប្រគល់កិច្ចសន្យាឱ្យ ឬចំពោះសហសេវិក សហការី និងញាតិសន្តានរបស់យើងខ្ញុំឡើយ។

ធ្វើនៅ................ថ្ងៃទី.........ខែ............ឆ្នាំ............

**ហត្ថលេខា និងឈ្មោះ/តួនាទី**

